ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# គោលការណ៍ណែនាំក្រមសីលធម៌

# សំរាប់

# ការសិក្សាស្រាវជ្រាវសុខភាព

# ដែលទាក់ទងនឹងមនុស្ស

ខែមករា ឆ្នាំ ២០០១

# គោលការណ៍ណែនាំក្រមសីលធម៌សំរាប់ការស្រាវជ្រាវសុខភាព ដែលទាក់ទងនឹងមនុស្ស

រាល់ការងារស្រាវជ្រាវសុខភាព ដែលទាក់ទងនឹងមនុស្ស ត្រូវអនុវត្តទៅតាមគោលការណ៍ក្រមសីលធមិជាមូលដ្ឋានបី ពោលគឺ :

១- គុណធមិ ដែលតំរូវឱ្យកើតនូវអំពើជាកុសលៈ ត្រូវចៀសវាងនូវផលប៉ះពាល់ ឬផលប្រយោជន៍ ត្រូវគិតទៅដល់ហានិភ័យ និង ការប៉ះពាល់ដែលអាចកើតមាន .

២- ការគោរពសិទ្ធ : រួមមានការជ្រើសរើសដោយសេរី របស់សាមីខ្លួន និងការការពារចំពោះអ្នកដែលមានការថមថយស្វ័យភាព. និង

៣- យុត្តិធមិ ដែលទាមទារឱ្យមានការបែងចែកស្មើៗ គ្នានូវបន្ទុក និង ផលប្រយោជន៍ ។

## ផ្នែកទី១

## ការសិក្សាពិសោធន៍ និង ការសិក្សាគ្លីនិក

រាល់គំរោងដែលស្នើសុំធ្វើការសិក្សាពិសោធន៏និងការសិក្សាគ្លីនិកត្រូវឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យក្រមសីលធមិដូចខាងក្រោមដែលទាក់ទងនឹងការព្រមព្រៀងជាមុននៃសាមីជនការជ្រើសរើសសាមីជនដើម្បីស្រាវជ្រាវ ការរក្សាការសម្ងាត់អំពីទិន្នន័យនិងការផ្តល់សំណងចំពោះការរងរបួសដោយចៃដន្យ ។

## ក_ការព្រមព្រៀងជាមុននៃសាមីជន

<u>ប្រការ១</u>: *ការព្រមព្រៀងជាមុនក្នុងលក្ខណៈជាបុគ្គល*

រាល់ការស្រាវជ្រាវពិសោធន៏និងការស្រាវជ្រាវគ្លីនិកដែលទាក់ទងនឹងមនុស្ស អ្នកស្រាវជ្រាវត្រូវតែទទួលបាននូវការព្រមព្រៀងជាមុនអំពីសាមីជនដែលបំរុងប្រគល់ខ្លួនឱ្យធ្វើការស្រាវជ្រាវឬការព្រមព្រៀងជំនួសពីអ្នកតំណាងម្នាក់ដែលបានទទួលការអនុញ្ញាតិត្រឹមត្រូវក្នុងករណីដែលបុគ្គលនោះមិនអាចផ្តល់នូវការព្រមព្រៀងបាន ។ការប្រើប្រាក់កាស.សំភារៈឬមធ្យោបាយផ្សេងទៀតក្នុងការអូសទាញឱ្យមានការព្រមព្រៀងត្រូវហាមឃាត់ ។

<u>ប្រការ២</u>: *ពត៌មានសំខាន់ៗ សំរាប់សាមីជនដែលបំរុងផ្តល់ខ្លួនឱ្យធ្វើការស្រាវជ្រាវ*

អ្នកស្រាវជ្រាវត្រូវផ្តល់ពត៌មានជាមុនដល់សាមីជនដែលព្រមព្រៀងចូលរួមក្នុងការស្រាវជ្រាវដោយប្រើភាសាដែលអ្នកនោះអាចយល់បានអំពី :

- ប្រធានបទ.គោលបំណង និង វិធីសាស្រ្ត នៃការស្រាវជ្រាវ

- រយៈពេលរំពឹងទុកនៃការចូលរួមរបស់អ្នកនោះ
- ផលប្រយោជន៍ដែលអាចរំពឹងទុកដោយសមហេតុផល ចំពោះបុគ្គលនោះ ឬអ្នកផ្សេងទៀត ដែលជាលទ្ធផលនៃ ការស្រាវជ្រាវ ។
- ហានិភ័យ ឬភាពមិនកក់ក្តៅទាំងឡាយណាដែលអាចកើតមានចំពោះអ្នកនោះ ដែលទាក់ទងទៅនឹងការចូលរួមក្នុងការស្រាវជ្រាវ ។
- ទំរង់ការ ឬវិធីព្យាបាលផ្សេងទៀត ដែលអាចមានសារៈប្រយោជន៍ដល់អ្នកនោះ ដូចទំរង់ការ ឬការព្យាបាលដែលគេកំពុងសាកល្បងនេះ ។
- កំរិតនៃការរក្សាការសំងាត់ឱ្យបាន នៅពេលអនាគតលើកំណត់ត្រានានា ដែលគេអាចសំគាល់អត្តសញ្ញាណ របស់អ្នកនោះ ។
- កំរិតនៃការទទួលខុសត្រូវរបស់អ្នកស្រាវជ្រាវ( ប្រសិនបើមាន) ក្នុងការផ្តល់សេវាព្យាបាលចំពោះបុគ្គលនោះ ។
- ការព្យាបាលនឹងត្រូវផ្តល់ជូនដោយឥតគិតថ្លៃចំពោះប្រភេទជាក់លាក់នៃរបួស ឬ ផលវិបាកដែលទាក់ទងនឹងការស្រាវជ្រាវ ។
- ថាតើបុគ្គលឬក្រុមគ្រួសារ ឬសាច់ញាតិរបស់បុគ្គល នឹងត្រូវផ្តល់សំណងចំពោះពិការភាពឬមរណៈភាព ដែលបណ្តាលពីរបួសបែបនោះ ,និង
- ថាសាមុីជននោះមានសេរីភាពក្នុងការប្រកែកមិនចូលរួមនិង នឹង មានសេរីភាពក្នុងការដកខ្លួនចេញពី ការស្រាវជ្រាវនៅពេលណាក៏បាន ដោយគ្មានរងនូវការ ពិន័យ ឬបាត់បង់ផលប្រយោជន៍ដែលជននោះ មានសិទ្ធិទទួល ។

<u>ប្រការ៣</u>: *កាតព្វកិច្ចអ្នកស្រាវជ្រាវទាក់ទងនឹងការព្រមព្រៀងជាមុន*

អ្នកស្រាវជ្រាវមានភារៈកិច្ច :

- ផ្តល់ជូនអនាគតសាមុីជននូវរាល់ពត៌មានចាំបាច់ ដើម្បីឱ្យមានការព្រមព្រៀងសមស្របជាមុន
- ផ្តល់ឱកាស និង ការលើកទឹកចិត្តគ្រប់គ្រាន់ ដល់អនាគតសាមុីជនក្នុងការសាកសួរ
- ចៀសវាងនូវលទ្ធភាព នៃការបោកប្រាស់ ការប្រើឥទ្ធិពលជ្រុលហួសហេតុ និងការគំរាមកំហែង
- ស្វែងរកការព្រមព្រៀងបន្ទាប់ពីពេលដែលអនាគតសាមុីជនបានទទួលការយល់ដឹងបានគ្រប់គ្រាន់អំពីហេតុការណ៍ដែលពាក់ព័ន្ធនានានិងអំពីផលវិបាកនៃការចូលរួមហើយមានឱកាសពេញលេញក្នុងការសំរេចចិត្តថា តើត្រូវចូលរួម ឬយ៉ាងណាតែប៉ុណ្ណោះ
- ជានិច្ចកាលត្រូវទទួលពីអនាគតសាមុីជនម្នាក់ៗនូវក្រដាសបំពេញដែលមានចុះហត្ថលេខាជា ភ័ស្តុតាងនៃការព្រមព្រៀងជាមុន ហើយនិង
- ត្រូវធ្វើកិច្ចព្រមព្រៀងសារជាថ្មីចំពោះសាមុីជនម្នាក់ៗប្រសិនបើមានការផ្លាស់ប្តូរអំពីល័ក្ខខ័ណ្ឌ ឬ ទំរង់ការនៃការស្រាវជ្រាវ ។

ប្រការ៤: *ការទាក់ទាញអោយចូលរួម*

- សាម៉ីជនដែលចូលរួមក្នុងការស្រាវជ្រាវគ្លីនិក ត្រូវបានបង់ថ្លៃចំពោះភាពមិនអំណោយផល និងការខាតបង់ពេលវេលា ។
- សាម៉ីជនទាំងអស់ ត្រូវបានទទួលសំណង សំរាប់រាល់ការចំណាយ ដែលទាក់ទងនឹងការចូលរួមរបស់ខ្លួន ក្នុងការស្រាវជ្រាវ ហើយក៏អាចទទួលសេវាព្យាបាល ដោយឥតគិតថ្លៃ។
- ទំហំនៃការទូទាត់ ឬសេវាព្យាបាលមិនត្រូវមានចំនួនច្រើនពេកទេ និង ត្រូវមានការយល់ព្រមពីគណៈកម្មការត្រួតពិនិត្យក្រមសីលធម៌ ។

ប្រការ៥: *ការស្រាវជ្រាវទាក់ទងនឹងកុមារ*

- រាល់ការស្រាវជ្រាវដែលទាក់ទងនឹងកុមារ អ្នកស្រាវជ្រាវមិនត្រូវធ្វើការស្រាវជ្រាវដូចធ្វើចំពោះមនុស្សពេញវ័យទេ
- ក្នុងករណីចាំបាច់សំរាប់ការស្រាវជ្រាវអំពីជម្ងឺកុមារភាពនិងល័ក្ខខ័ណ្ឌនានាដែលងាយនឹងកើតមានចំពោះកុមារ ជានិច្ចកាលត្រូវមានការព្រមព្រៀងពីឪពុកម្តាយឬអាណាព្យាបាលស្របច្បាប់បន្ទាប់ពីធ្វើការពន្យល់ឱ្យបានពេញលេញអំពីគោលបំណងនៃការពិសោធន៍ហើយនិងគ្រោះថ្នាក់ឬភាពមិនអំណោយផលនានា ដែលអាចកើតមាន ។

ប្រការ៦: *ការស្រាវជ្រាវដែលទាក់ទងនឹងជនដែលមានពិការភាពខាងស្មារតី ឬផ្លូវចិត្ត*

- មិនត្រូវយកជនដែលមានពិការភាពខាងស្មារតីមកធ្វើការសិក្សាស្រាវជ្រាវ ដូចមនុស្សពេញវ័យ ដែលមានសុខភាពស្មារតីល្អទេ.
- ការសិក្សាស្រាវជ្រាវលើជនទាំងនេះ អំពីមូលហេតុ និងការព្យាបាល ត្រូវមានការព្រមព្រៀងពីក្រុមគ្រួសារផ្ទាល់ ដូចជាប្តី ឬប្រពន្ធ ឪពុកម្តាយ កូនពេញវ័យ ឬបងប្អូនរបស់ជននោះ ។

ប្រការ៧: *ការស្រាវជ្រាវដែលទាក់ទងនឹងទណ្ឌិត*

- ចំពោះទណ្ឌិត.ការអនុវត្តត្រូវធ្វើតាមល័ក្ខខ័ណ្ឌដូចគ្នានឹងអ្នកដទៃទៀតដែលចែងនៅក្នុងផ្នែកទី១ ប្រការ២ ។មុននឹងធ្វើការស្រាវជ្រាវត្រូវមានកិច្ចព្រមព្រៀងពីអ្នកទាំងនោះជាមុន ។ការស្រាវជ្រាវលើទណ្ឌិតដែលមានជម្ងឺធ្ងន់ធ្ងរ ឬ ជម្ងឺងាយវិវត្តន៍ទៅរកភាពធ្ងន់ធ្ងរត្រូវហាមឃាត់ ។

## ២/ ការជ្រើសរើសសាម៉ីជនដើម្បីធ្វើការស្រាវជ្រាវ

ប្រការ៨: *ការបែងចែកបន្ទុក និងផលប្រយោជន៍ដោយសមធម៌*

- ការបែងចែកបន្ទុក និងផលប្រយោជន៍ ត្រូវធ្វើឡើងដោយសមធម៌ ចំពោះសាម៉ីជន ឬសហគមន៍ទាំងឡាយណាដែលត្រូវបានជ្រើសរើសមកធ្វើជាសាម៉ីជន នៃការស្រាវជ្រាវ .

-ការជ្រើសរើសអ្នកទន់ខ្សោយត្រូវតែអនុវត្តអោយបានត្រឹមត្រូវអំពីមធ្យោបាយការពារសិទ្ធិ និងសុខមាលភាពអ្នកទាំងនោះ ។

-សមភាពនៃភេទ ត្រូវតែគោរព

<u>ប្រការ៩</u>: *ការជ្រើសរើសយកស្ត្រីមានគភ៌ ឬស្ត្រីបំបៅដោះមកធ្វើជាសាម៉ីជននៃការស្រាវជ្រាវ*

- ការជ្រើសរើសយកស្ត្រីមានគភ៌ ឬស្ត្រីបំបៅដោះមកធ្វើជាសាម៉ីជននៃការស្រាវជ្រាវគ្លីនិកណាមួយ ត្រូវហាមឃាត់,លើកលែងតែក្នុងករណីដែលការស្រាវជ្រាវបែបនោះអាចត្រូវបានកំណត់ឡើង សំរាប់ ការពារ ឬបង្កើនសុខភាពស្ត្រីមានផ្ទៃពោះ ឬស្ត្រីបំបៅដោះ ឬសុខភាពរបស់គភ៌ ឬសុខភាពទារក ហើយស្ត្រីដែលគ្មានគភ៌ឬមិនបំបៅដោះ មិនមែនជាសាម៉ីជនសមស្របសំរាប់ការស្រាវជ្រាវនោះ ។

## គ/ ការសំងាត់នៃទិន្នន័យ

<u>ប្រការ១០</u>: *ការរក្សាការសំងាត់*

អ្នកស្រាវជ្រាវត្រូវរក្សាការសំងាត់អំពីទិន្នន័យនៃការស្រាវជ្រាវ ។គេត្រូវប្រាប់ជាមុនដល់សាម៉ីជនដែលចូលរួមធ្វើការស្រាវជ្រាវអំពីព្រំដែននៃលទ្ធភាពរបស់អ្នកស្រាវជ្រាវក្នុងការរក្សាការសំងាត់ និង អំពីផលវិបាកនានា ដែលអាចកើតមានប្រសិនបើការរក្សាការសំងាត់នោះ មានការធ្វេះធ្វោយ ។

## ឃ/ សំណងដល់សាម៉ីជនដែលចូលរួមធ្វើការស្រាវជ្រាវក្នុងករណីរបួសដោយចៃដន្យ

<u>ប្រការ១១</u>: *សិទ្ធិទទួលសំណងនៃសាម៉ីជន*

សាម៉ីជនដែលចូលរួមធ្វើការស្រាវជ្រាវហើយរងរបួសខាងផ្លូវកាយដោយផ្ទាល់ ឬដោយ ប្រយោលដោយសារការចូលរួមក្នុងការស្រាវជ្រាវ( ឧទាហរណ៍ដូចជាគ្រោះថ្នាក់ចរាចរដែលអាចកើតឡើងចំពោះបុគ្គលនោះក្នុងពេលធ្វើដំណើរទៅកាន់កន្លែងសិក្សាស្រាវជ្រាវ) ត្រូវបានទទួល សំណងហិរញ្ញវត្ថុ ឬជំនួយឧបត្ថម្ភដទៃទៀតឱ្យបានសមធម៌ចំពោះការខូចខាតឬពិការភាពបណ្តោះអាសន្នឬជារៀងរហូត ។ក្នុងករណីមានការបាត់បង់ជីវិតទាយាទរបស់ជនទាំងនោះត្រូវទទួលសំណងជំនួស ។គេមិនត្រូវធ្វើមិនដឹងមិនឮ អំពីសិទ្ធិទទួលសំណងនោះទេ ។

## ង/ ទិន្នន័យ និង លទ្ធផល នៃការសិក្សា

<u>ប្រការ១២</u>: *របាយការណ៍ និង ទិន្នន័យនៃការសិក្សា*

ការស្រាវជ្រាវណាក៏ដោយដែលធ្វើនៅព្រះរាជាណាចក្រកម្ពុជាទោះបីជាឧបត្ថម្ភគាំទ្រឬគ្រប់គ្រងដោយស្ថាប័នក្នុងស្រុកឬដោយបរទេសក្តីគេត្រូវតែតំកល់របាយការណ៍ស្តីពីការស្រាវជ្រាវនោះមួយច្បាប់នៅវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈហើយទិន្នន័យនៃរបាយការណ៍ទាំងនោះគឺជាទិន្នន័យរបស់ជាតិ ។

<u>ប្រការ១៣</u>: *ការផ្សព្វផ្សាយអំពីលទ្ធផល នៃការសិក្សា*

លទ្ធផលនៃការសិក្សាត្រូវតែផ្សព្វផ្សាយជាសាធារណៈដោយគ្មានការជ្រៀតជ្រែកពីអាជ្ញាធររដ្ឋបាល ឬអ្នកឧបត្ថម្ភគាំទ្រឡើយ ។

# ផ្នែកទី ២

## ការស្រាវជ្រាវអេពីដេមីសាស្ត្រដោយសង្កេត

សំណើសុំធ្វើការស្រាវជ្រាវអេពីដេមីសាស្ត្រដោយសង្កេតត្រូវគោរពទៅតាមលក្ខណៈវិនិច្ឆ័យក្រមសីលធម៌ដែលទាក់ទងនឹងបញ្ហាការព្រមព្រៀងជាមុន,ការបង្កើនផលប្រយោជន៍ឱ្យបានខ្ពស់បំផុត,កាត់បន្ថយផលប៉ះពាល់ឱ្យនៅតិចបំផុត,ការរក្សាការសំងាត់និងចៀសវាងជំលោះអំពីផលប្រយោជន៍នៃការស្រាវជ្រាវ ។

### ក/ ការព្រមព្រៀងជាមុន

<u>ប្រការ១:</u> *ការព្រមព្រៀងជាមុនក្នុងលក្ខណៈជាបុគ្គល*

តាមធម្មតាគេត្រូវស្វែងរកការព្រមព្រៀងរបស់គេជាមុននៅពេលដែលបុគ្គលទាំងឡាយត្រូវបានគេយកមកធ្វើសាម៉ីជននៃការសិក្សាអេពីដេមីសាស្ត្រដោយសង្កេត។ ការព្រមព្រៀងមានលក្ខណៈ "*ជាមុន*" នៅពេលដែលការព្រមព្រៀងនោះត្រូវបានផ្តល់ដោយបុគ្គលម្នាក់ដែលយល់អំពីគោលបំណងនិងចរិតនៃការស្រាវជ្រាវ យល់អំពី អ្វីដែលការស្រាវជ្រាវតំរូវអោយបុគ្គលនោះធ្វើ និង ប្រថុយនឹងហានិភ័យ និងពីផលប្រយោជន៍ដែលជាលទ្ធផល នៃការស្រាវជ្រាវនោះ ។

មានប្រភេទនៃការស្រាវជ្រាវអេពីដេមីសាស្ត្រដោយសង្កេតមួយចំនួនដែលការព្រមព្រៀងជាមុនមិនអាចយកមកអនុវត្តឬផ្តល់ការប្រឹក្សាបាន ។នៅក្នុងករណីបែបនេះគណៈកម្មការក្រមសីលធម៌ត្រូវកំណត់ឱ្យបានសមរម្យថាតើអាចទទួលយកបានតាមបែបសីលធម៌ដែរឬទេក្នុងការបន្តធ្វើការសិក្សាដោយមិនចាំបាច់មានការព្រមព្រៀងជាមុនអំពីបុគ្គលនិងថាតើផែនការរបស់អ្នកស្រាវជ្រាវក្នុងការការពារសុវត្ថិភាពនិងគោរពលក្ខណៈបុគ្គលភាពចំពោះសាម៉ីជនក្នុងការស្រាវជ្រាវនិងក្នុងការរក្សាការសំងាត់អំពីទិន្នន័យមានលក្ខណៈគ្រប់គ្រាន់ ដែរឬទេ ។

<u>ប្រការ២:</u> *កិច្ចព្រមព្រៀងរបស់សហគមន៍*

គេអាចស្វែងរកកិច្ចព្រមព្រៀងរបស់តំណាងសហគមន៍ឬតំណាងក្រុមនៅពេលដែលគេមិនអាចស្នើសុំការយល់ព្រមជាមុនពីបុគ្គលម្នាក់ៗដែលត្រូវធ្វើការសិក្សាស្រាវជ្រាវឬក៏នៅពេលណាដែលគេត្រូវចំណាយពេលវេលាច្រើនហួសហេតុក្នុងការស្នើសុំការព្រមព្រៀងនោះ ។ប៉ុន្តែគេត្រូវតែគោរពចំពោះការជំទាស់របស់បុគ្គលក្នុងការចូលរួមក្នុងការសិក្សា ។

<u>ប្រការ៣:</u> *ការបង្ហើបឱ្យដឹងអំពីពត៌មានខ្លះៗ*

ចំពោះការសិក្សាស្រាវជ្រាវអេពីដេមីសាស្ត្រដោយសង្កេតមួយចំនួន,គេមិនអាចអនុញ្ញាតិឱ្យមានការបង្ហើបពត៌មានឱ្យដឹងជាមុនទេ,ទោះជាមានសារៈសំខាន់យ៉ាងណាក៏ដោយ ។ធ្វើយ៉ាងនេះគឺសំដៅមិនឱ្យមានការជះឥទ្ធិពលដល់ការប្រព្រឹត្តទៅដោយឯកឯងក្នុងការតាមដាននិងចៀសវាងការទទួលចំលើយដែលអ្នកឆ្លើយ

អាចផ្តល់ដើម្បីឱ្យអ្នកស្រាវជ្រាវសប្បាយចិត្ត ។គណៈកម្មការក្រមសីលធមិអាចបង្ហើបឱ្យដឹងតែចំពោះពត៌មានមួយចំនួននៅពេល ដែលត្រូវបានគេ គិតគូរត្រឹមត្រូវរួចហើយ ។

## ខ/ ការទាញផលឱ្យបានជាអតិបរិមា

<u>ប្រការ៤:</u> *ការផ្តល់ពត៌មានអំពីលទ្ធផលនៃការសិក្សា*

របកគំហើញនានា នៃការស្រាវជ្រាវនិង ដំបូន្មានចំពោះសហគមន៍ត្រូវតែផ្តល់ដំណឹងទៅឱ្យ សហគមន៍ និងទៅឱ្យអាជ្ញាធរសុខាភិបាលតាមមធ្យោបាយសមស្របដែលគេមាន ។

<u>ប្រការ៥:</u> *ការថែទាំសុខភាពចំពោះសហគមន៍*

ការអនុវត្តន៍នូវកម្មវិធីស្រាវជ្រាវអេពីដេមីសាស្ត្រដោយសង្កេតអាចបង្កើតក្តីរំពឹងទុកក្នុងសហគមន៍ ដែលពាក់ព័ន្ធថាកម្មវិធីនោះនឹងផ្តល់ការថែទាំសុខភាពអោយដល់សហគមន៍នោះយ៉ាងហោចណាស់ក៏នៅពេល ដែលបុគ្គលិកស្រាវជ្រាវមានវត្តមាននៅទីនោះ ។គេមិនត្រូវធ្វើអ្វីឱ្យក្តីរំពឹងបែបនេះរលាយសាបសូន្យទៅវិញ នោះទេមានន័យថានៅទីណាដែលប្រជាជនត្រូវការសេវាថែទាំសុខភាពគេត្រូវផ្តល់សេវានោះដើម្បីឱ្យអ្នកទាំង នោះទទួលការពិនិត្យព្យាបាលឬក៏ត្រូវបញ្ជូនគេទៅសេវាសុខភាពមូលដ្ឋានដែលអាចផ្តល់ការថែទាំសុខភាពដែលចាំបាច់ ។

<u>ប្រការ៦:</u> *ការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាលមូលដ្ឋាន*

នៅក្នុងកំឡុងពេលដែលការសិក្សាស្រាវជ្រាវកំពុងតែដំណើរការទៅមុខ គេត្រូវឆ្លៀត ឱកាស ធ្វើការ បណ្តុះបណ្តាលបុគ្គលិកសុខាភិបាលមូលដ្ឋានអំពីជំនាញនិងបច្ចេកទេសដែលគេ អាចប្រើប្រាស់ដើម្បីបង្កើនសេវាសុខាភិបាល(ដូចជាលទ្ធភាពក្នុងការតាមដានជាប្រចាំអំពីអត្រាជម្ងឺ ឬអត្រាមរណៈភាព) ។

## គ/ ការធ្វើឱ្យផលប៉ះពាល់មានចំនួនតិចបំផុត

<u>ប្រការ៧:</u> *ការបង្កឱ្យមានផលប៉ះពាល់ និង ការប្រព្រឹត្តខុសឆ្គង*

អ្នកស្រាវជ្រាវដែលរៀបចំផែនការការសិក្សា ត្រូវចៀសវាងហានិភ័យដែលបង្កឱ្យមានផលប៉ះពាល់ ក្នុង ន័យដែលនាំមកនូវចំនុចខ្វះខាត និង ការប្រព្រឹត្តកំហុសដោយបំពាន ។

<u>ប្រការ៨:</u> *ការបង្ការមិនឱ្យមានផលប៉ះពាល់ទៅលើក្រុមនានា*

ការសិក្សាស្រាវជ្រាវអេពីដេមីសាស្ត្រដោយសង្កេតអាចធ្វើឱ្យក្រុមក៏ដូចជាបុគ្គលនានាប្រឈមមុខនឹង ផលប៉ះពាល់ ដូចជាការខាតបង់ខាងសេដ្ឋកិច្ចការបាត់បង់កិត្តិយសការរិះគន់ឬក៏ការឈប់ផ្តល់សេវា ។ក្នុងខណៈ ដែលអ្នកស្រាវជ្រាវបានរកឃើញនូវពត៌មានដែលធ្វើឱ្យក្រុមមួយងាយរងនូវការរិះគន់ឬការប្រព្រឹត្តជាអវិជ្ជមាននោះគេត្រូវប្រុងប្រយ័ត្នក្នុងការផ្តល់ពត៌មាននិងការពន្យល់អំពីរបកគំហើញរបស់ខ្លួន ។

## ឃ/ ការសំងាត់

<u>ប្រការ ៩:</u> *ការសំងាត់*

អ្នកស្រាវជ្រាវត្រូវមានវិធីសំរាប់រក្សាការពារការសំងាត់លើទិន្នន័យដែលទាក់ទងនឹងបុគ្គល ឬ ក្រុម ដែលប្រសិនបើលេចឮដល់ភាគីទីបីអាចធ្វើអោយមានការប៉ះពាល់ឬការមួហ្មង ។គេអាចដោះស្រាយដោយលុបបំបាត់ពតិមានដែលអាចនាំទៅរកអត្តសញ្ញាណនៃសាម៉ីបុគ្គលឬក៏ដាក់កំហិតមិនផ្តល់ទិន្នន័យទាំងស្រុង ឬ អាចធ្វើ ដោយមធ្យោបាយផ្សេងទៀត ។

## ង/ ជំលោះអំពីផលប្រយោជន៍

<u>ប្រការ ១០:</u> *ការកំណត់អត្តសញ្ញាណ នៃជំលោះអំពីផលប្រយោជន៍*

អ្នកស្រាវជ្រាវមិនត្រូវបិទបាំងជំលោះអំពីផលប្រយោជន៏ជាមួយនឹងសហការីអ្នកឧបត្ថម្ភការសិក្សាស្រាវជ្រាវឬសាម៉ីជនឡើយ ។អ្នកស្រាវជ្រាវត្រូវជំរាបជូនដល់គណៈកម្មការក្រមសីលធម៌នូវជំលោះអំពីផលប្រយោជន៏ដែលបំរុងនឹងកើតឡើង ។ជំលោះអាចកើតមាននៅពេលណាដែលអង្គការពាណិជ្ជកម្មណាមួយឬក៏អ្នកឧបត្ថម្ភមានបំណងយកលទ្ធផលនៃការសិក្សាស្រាវជ្រាវទៅជំរុញលទ្ធផលឬសេវាណាមួយ ឬ ក៏នៅពេលណាដែលមិនអាច ជំរាបជូនអំពីរបកគំហើញ ដោយសារឧបសគ្គ ខាងផ្នែកនយោបាយ ។

<u>ប្រការ ១១:</u> *ភាពសត្យានុម័ត និងការជំរុញគាំទ្រតាមបែបវិទ្យាសាស្ត្រ*

ភាពស្មោះត្រង់និងភាពមិនលំអៀងមានសារៈសំខាន់ណាស់ក្នុងការគ្រោងនិងរៀបចំការសិក្សាក្នុងការបង្ហាញនិងការបកស្រាយរបកគំហើញ ។គេមិនត្រូវផ្អិបទិន្នន័យទុកឬបកស្រាយមិនបានត្រឹមត្រូវឬកែប្រែទិន្នន័យទេ ។អ្នកស្រាវជ្រាវអាចរកឃើញគ្រោះថ្នាក់ចំពោះសុខភាពដែលទាមទារឱ្យមានការកែតំរូវហើយគេប្រែក្លាយទៅជាអ្នកជំរុញគាំទ្រដើម្បីការពារនិងស្តារសុខភាពឡើងវិញ ។នៅក្នុងសភាពបែបនេះ ការគាំទ្ររបស់គេ ត្រូវតែឈរលើទិន្នន័យដែលមានលក្ខណៈ សត្យានុម័ត និង វិទ្យាសាស្ត្រ ។

## ច/ ទិន្នន័យ និងលទ្ធផលនៃការសិក្សា

<u>ប្រការ ១២:</u> *របាយការណ៍និងទិន្នន័យ នៃការសិក្សា*

ការស្រាវជ្រាវណាក៏ដោយដែលធ្វើនៅព្រះរាជាណាចក្រកម្ពុជាទោះបីជាឧបត្ថម្ភគាំទ្រ ឬ គ្រប់គ្រងដោយស្ថាប័នក្នុងស្រុកឬដោយបរទេសក្តីគេត្រូវតំកល់របាយការណ៍ស្តីពីការស្រាវជ្រាវនោះមួយច្បាប់នៅវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ ហើយទិន្នន័យនៃរបាយការណ៍ទាំងនោះគឺជាទិន្នន័យរបស់ជាតិ ។

ប្រការ ១៣: *ការផ្សព្វផ្សាយអំពីលទ្ធផលនៃការសិក្សា*

លទ្ធផលនៃការសិក្សាត្រូវតែផ្សព្វផ្សាយជាសាធារណៈដោយគ្មានការជ្រៀតជ្រែកពីអាជ្ញាធររដ្ឋបាល ឬអ្នក ឧបត្ថម្ភ គាំទ្រឡើយ ។

## ផ្នែកទី ៣

## ក/ នីតិវិធីពិនិត្យក្រមសីលធម៌សារជាថ្មី

គោលបំណងនៃការពិនិត្យឡើងវិញនូវក្រមសីលធម៌គឺពិនិត្យមើលនូវចំណុចទាំងឡាយនៃគំរោងស្នើសុំធ្វើការសិក្សាស្រាវជ្រាវដោយផ្អែកទៅលើគោលការណ៍ក្រមសីលធម៌នានាដើម្បីឱ្យប្រាកដថាអ្នកស្រាវជ្រាវបានប្រមើលមើលជាមុនហើយដោះស្រាយឱ្យបានសមស្របនូវវិវុទ្ធភាពក្រមសីលធម៌នានាដែលអាចមានព្រមទាំងធ្វើការវាយតម្លៃអំពីការឆ្លើយតបរបស់អ្នកទាំងនោះ ចំពោះបញ្ហាក្រមសីលធម៌ដែលការសិក្សានេះបានលើកឡើង ។

ប្រការ ១: *កិច្ចតំរូវអំពីការពិនិត្យមើលឡើងវិញនូវក្រមសីលធម៌*

អ្នកឧបត្ថម្ភគាំទ្រនិងអ្នកស្រាវជ្រាវត្រូវបានស្នើឱ្យដាក់គំរោងរបស់ខ្លួនទៅឱ្យគណៈកម្មការក្រមសីលធម៌ដើម្បីពិនិត្យមើលសារជាថ្មី ។ករណីនេះត្រូវអនុវត្តចំពោះរាល់គំរោងពោលគឺគំរោងបែបសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ,គំរោងរដ្ឋាភិបាល,គំរោងថែទាំសុខភាព,គំរោងមានលក្ខណៈពាណិជ្ជកម្មនិង គំរោងប្រភេទផ្សេងទៀត លើកលែងតែការអង្កេតជាទៀងទាត់ដែលគេតំរូវក្នុងគោលបំណងតាមដាននិងវាយតម្លៃ ។ករណីនេះក៏ត្រូវអនុវត្តផងដែរចំពោះការសិក្សាដែលឧបត្ថម្ភគាំទ្រមកពីបរទេសត្រូវផ្តល់ការបណ្តុះបណ្តាលជូនបុគ្គលិកសុខាភិបាលមូលដ្ឋានអោយចេះអនុវត្តគំរោងសិក្សាបែបដូចគ្នានេះដោយខ្លួនឯង ។ចំពោះការតាមដាននិងវាយតម្លៃគំរោង ឬជំរឿនប្រជាជន,កិច្ចព្រមព្រៀងទូទៅស្របទៅតាមគោលការណ៍ណែនាំរបស់រដ្ឋាភិបាល ត្រូវជាផ្នែកមួយ នៃ កិច្ចព្រមព្រៀងនានា របស់គំរោង ។

ក៏ប៉ុន្តែការលើកលែងមួយអាចធ្វើទៅបានគឺនៅពេលដែលអ្នកជំនាញខាងអេពីដេមីសាស្ត្រត្រូវធ្វើការតាមដានការផ្ទុះការរាតត្បាតនៃជម្ងឺឆ្លង ។ទោះបីជាយ៉ាងណាក៏ដោយនៅក្នុងករណីបែបនេះអ្នកតាមដាន,នោះត្រូវគោរ ពសិទ្ធិនានារបស់បុគ្គលមានជាអាទិ៍ សេរីភាព បុគ្គលភាព និងការសំងាត់ ។

<u>ប្រការ ២:</u> *ពត៌មានដែលអ្នកស្រាវជ្រាវត្រូវផ្តល់*

អ្នកស្រាវជ្រាវត្រូវរៀបចំពិធីសារលំអិត ក្នុងនោះរួមមាន :

- សេចក្តីបញ្ជាក់យ៉ាងច្បាស់អំពីវត្ថុបំណង ដោយ និយាយអំពីស្ថានភាពបច្ចុប្បន្ន នៃការយល់ដឹង និង ភាពសមហេតុសមផលក្នុងការតាមដានលើខ្លួនមនុស្ស;
- ការពណ៌នាយ៉ាងជាក់លាក់អំពីនីតិវិធីស្នើឡើងទាំងអស់និងអន្តរាគមន៍នានារួមមានកំរិតឱសថដែលមាន បំណងនឹងប្រើហើយនិង រយៈពេលគ្រោងធ្វើការព្យាបាល ;
- ផែនការស្ថិតិដែលបង្ហាញអោយឃើញចំនួនសាមុីជនដែលត្រូវចូលរួម;
- លក្ខណៈវិនិច្ឆ័យសំរាប់បញ្ចប់ការសិក្សាស្រាវជ្រាវ និង
- លក្ខណៈវិនិច្ឆ័យសំរាប់កំណត់ការសំរេចជ្រើសរើស ឬ ការដកចេញនូវសាមុីជនម្នាក់ៗ ដោយមានបញ្ជាក់ លំអិតអំពីនីតិវិធីក្នុងការទទួលការព្រមព្រៀងជាមុន ។

ពិធីសារនោះក៏ត្រូវ :

- ដាក់បញ្ចូលពត៌មានក្នុងការបង្កើតសុវត្ថិភាពចំពោះនីតិវិធី និង អន្តរាគមន៍នីមួយៗ និងចំពោះ ឱសថ ឬវ៉ាក់សាំង ឬ ឧបករណ៍ដែលត្រូវធ្វើតេស្ត រួមទាំងលទ្ធផលដែលទាក់ទងនឹងមន្ទីរពិសោធន៍ និងការ ស្រាវ ជ្រាវចំពោះសត្វ ;

បញ្ជាក់ផលប្រយោជន៍ដែលអាចមានចំពោះសាមុីជនហើយនិងគ្រោះថ្នាក់ដែលអាចកើតមានអំពីនីតិវិធី ដែលបានស្នើ;

- បង្ហាញមធ្យោបាយនិងឯកសារដាក់ស្នើដែលត្រូវប្រើ សំរាប់ទទួលបាននូវការព្រមព្រៀងជាមុន ឬ នៅ ពេលណាដែលមិនអាចរកបាននូវការព្រមព្រៀងបែបនេះបញ្ជាក់ថាតើមានមធ្យោបាយដែលគេយល់ ព្រម ដទៃទៀតក្នុងការទទួលការព្រមព្រៀងដែលត្រូវប្រើ ហើយតើគេលើកសំណើយ៉ាងណាដើម្បីការ ពារ សិទ្ធិ និង ធានាសុខមាលភាពរបស់សាមុីជន;
- ផ្តល់ភ័ស្តុតាង ថា អ្នកស្រាវជ្រាវជាមានអ្នកសមត្ថភាពត្រឹមត្រូវ មានបទពិសោធន៍ ឬប្រសិនបើចាំបាច់ បង្ហាញថាធ្វើការជាមួយអ្នកអភិបាលដែលមានសមត្ថភាពហើយបង្ហាញថាអ្នកស្រាវជ្រាវមាន លទ្ធភាព ប្រើប្រាស់ឧបករណ៍សមស្របសំរាប់ធានាសុវត្ថិភាពនិងប្រសិទ្ធិភាពក្នុងការដំណើរការស្រាវជ្រាវហើយ និង
- រៀបរាប់អំពីមធ្យោបាយដែលបានស្នើឡើងដើម្បីរក្សាការសំងាត់នៅក្នុងអំឡុងពេលវិភាគនិងបោះ ផ្សាយ លទ្ធផល នៃការស្រាវជ្រាវ ។

ប្រការ ៣: *គណៈកម្មការក្រមសីលធម៌ :*

គណៈកម្មការក្រមសីលធម៌ជាគណៈកម្មការត្រួតពិនិត្យថ្នាក់ជាតិមួយដែលត្រូវបានបង្កើតឡើងដើម្បីពិនិត្យពិធីសារសិក្សាស្រាវជ្រាវដោយផ្អែកលើលក្ខណៈវិទ្យាសាស្ត្រ និង ផ្អែកលើ ក្រម សីលធម៌:

- គុណភាពនៃសំណើស្រាវជ្រាវត្រូវបានធ្វើការវាយតម្លៃថាជាសំណើសមស្របនិងមានលក្ខណៈវិទ្យាសាស្ត្រ;
- ត្រូវធ្វើការវាស់វែងទំនាក់ទំនងរវាងរាល់ការសិក្សាស្រាវជ្រាវទៅនឹងការចំណាយថាមពលនិងការវិនិយោគពេលវេលា និងធនធាន ព្រមទាំងហានិភ័យ និងលទ្ធផលរំពឹងទុក;
- ត្រូវចៀសវាងការសិក្សាស្រាវជ្រាវដែលមិនចាំបាច់ ។ គណៈកម្មការនេះជានិច្ចកាលត្រូវធ្វើការវិភាគថាតើមានការសិក្សាស្រាវជ្រាវណាដូចគ្នានេះនៅមិនទាន់បានធ្វើនៅឡើយនៅប្រទេសកម្ពុជា ។ លទ្ធផលដែលគេរំពឹងទុកត្រូវមានទំនាក់ទំនងគ្រប់គ្រាន់សំរាប់បន្ថែមចំណេះដឹងឬការអភិវឌ្ឍន៍យុទ្ធសាស្ត្រ ។

គណៈកម្មការនេះត្រូវបង្កើតរបៀបរបបធ្វើការងារដូចជាចំនួនដងនៃការប្រជុំ,កូរ៉ុមសំរាប់ដំណើរការប្រជុំ,នីតិវិធីក្នុងការធ្វើសេចក្តីសំរេចនិងការធ្វើការពិនិត្យឡើងវិញលើសេចក្តីសំរេច ។ សមាជិកភាពនៃគណៈកម្មការត្រួតពិនិត្យថ្នាក់ជាតិត្រូវមាននូវអ្នកជំនាញខាងអេពីដេមីសាស្ត្រ,អ្នកជំនាញស្ថិតិ,គ្រូពេទ្យ,សង្គមវិទូ,អ្នកច្បាប់,អ្នកជំនាញខាងមីក្រូជីវសាស្ត្រ,អ្នកជំនាញខាងឱសថការី ។អ្នកទាំងនោះត្រូវបានទទួលការចាត់តាំងពីរដ្ឋមន្ត្រីក្រសួងសុខាភិបាលដោយផ្អែកលើសមត្ថភាពនិងបូរណៈភាពការងារ ។ពួកគេអាចជាអ្នកធ្វើការនៅតាមនាយកដ្ឋាន និង វិទ្យាស្ថាននានានៃក្រសួងសុខាភិបាលនិងស្ថាប័នពាក់ព័ន្ធ។ អ្នកជំនាញការមកពីអង្គការសុខភាពពិភពលោក និង អង្គការពាក់ព័ន្ធនានា អាចជាទីប្រឹក្សាបច្ចេកទេស របស់ គណៈកម្មការនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី...១៨...ខែ.មករា ឆ្នាំ ២០០១

អគ្គនាយកបច្ចេកទេសសុខាភិបាល

សាស្ត្រាចារ្យ.អេង ហួត

**ឧបសម្ព័ន្ធទី ១**

*ការសិក្សាស្រាវជ្រាវពិសោធន៍* គឺជាការសិក្សាដែលអ្នកស្រាវជ្រាវធ្វើការផ្លាស់ប្តូរដោយចេតនានូវកត្តាមួយឬច្រើននៅក្នុងល័ក្ខខ័ណ្ឌដែលអ្នកនោះអាចគ្រប់គ្រងសភាពការណ៍បានដើម្បីសិក្សាលទ្ធផលនៃការធ្វើបែបនេះ ។ការសិក្សាពិសោធន៍ដែលទាក់ទងនឹងមនុស្សរួមមានការពិសោធន៍ (ក្នុងសហគមន៍ប្រជាជន និងគ្លីនិក) ដែលគេធ្វើឡើង ដើម្បីធ្វើតេស្តលើវិធីព្យាបាល ឬវិធីបង្ការរោគ ឬ បែបបទធ្វើរោគវិនិច្ឆ័យ ។

"*ការស្រាវជ្រាវតាមរយៈគ្លីនិក*" គឺជាពាក្យគេប្រើនៅក្នុងការសិក្សាទាំងឡាយដែលមានសមាសភាគមួយឬច្រើនដែលមានចរិតជាការសិក្សារោគវិនិច្ឆ័យការបង្ការឬជាការព្យាបាលហើយគេប្រើសំរាប់អនុវត្តចំពោះមនុស្ស ។ការស្រាវជ្រាវនេះក៏មានរាប់បញ្ចូលផងដែរ នូវការប្រើប្រាស់សារធាតុដែលគ្មានជាតិថ្នាំ,ការធ្វើតេស្តផ្នែកមន្ទីរពិសោធន៍និងមធ្យោបាយទាំងឡាយណាដែលគេប្រើប្រាស់ក្នុងគោលបំណងព្យាបាលនិងបង្ការជម្ងឺ ។

**ឧបសម្ព័ន្ធទី២:**

*ការស្រាវជ្រាវអេពីដេមីសាស្ត្រ ដោយសង្កេត* រួមមាន ការសិក្សាស្រាវជ្រាវបែបកាត់ទទឹង (Cross-Sectional Studies)(អង្កេត) ការស្រាវជ្រាវត្រួតពិនិត្យករណីនិងសាក្សី(Case- Control Studies)ព្រមទាំងការសិក្សាក្រុមជនដែលមានលក្ខណៈរួមគ្នា(Cohort Studies) ។ ការសិក្សាទាំងនេះមិនសូវមានប៉ះពាល់ចំពោះសាមីខ្លួនដែលគេធ្វើការសិក្សាទេ ។អ្នកទាំងនោះគ្មានទាក់ទងនឹងអន្តរាគមន៍អ្វីក្រៅពីការសាកសួរសំនួរ,ការពិនិត្យតាមបែបវេជ្ជសាស្ត្រហើយជូនកាលឆ្លងកាត់ការវិភាគមន្ទីរពិសោធន៍ឬការពិនិត្យដោយវិទ្យុសាស្ត្រ ។ តាមធម្មតា គេត្រូវមានការព្រមព្រៀងជាមុនថ្វីត្បិតតែមានការលើកលែងមួយចំនួនដូចជាការសិក្សាក្រុមជនដែលមានលក្ខណៈ រួមគ្នា ដែលមានចំនួនច្រើនតាមរយៈការពិនិត្យមើល នូវកំណត់ហេតុវេជ្ជសាស្ត្រ ។